Australian Government

Job Capacity Assessment

# ព័ត៌មានដ៏សំខាន់អំពី *JOB CAPACITY ASSESSMENT* របស់លោកអ្នក

## តើ *Job Capacity Assessment* ជាអ្វី?

*Job Capacity Assessment* គឺជាការណាត់ជួបមួយជាមួយ Job Capacity Assessor ដែលមានជំនាញគ្រប់លក្ខណៈក្នុងការពិនិត្យវាយតម្លៃសមត្ថភាពធ្វើការងាររបស់លោកអ្នក, ដោយសំអាងទៅលើព័ត៌មានដែលលោកអ្នកផ្តល់ឲ្យនៅក្នុងអំឡុងពេលនៃការណាត់ជួបនេះ ហើយនិងព័ត៌មានពាក់ព័ន្ធដទៃទៀត, ដូចជារបាយការណ៍ពេទ្យជាដើម។

Job Capacity Assessors ជាអ្នកមានវិជ្ជាជីវៈរួមសម្ព័ន្ធខាងសុខភាព, ដូចជាអ្នកចិត្តសាស្ត្រ, អ្នកព្យាបាលរោគដោយកាយវប្បកម្មហើយនិងទីប្រឹក្សាខាងការធ្វើឲ្យបានល្អឡើងវិញ។ ទីណាដែលអាចធ្វើទៅបាន, Job Capacity Assessor នេះនឹងប្រាប់លោកអ្នកឲ្យទៅរកសេវាទាំងឡាយដែលអាចជួយលោកអ្នករកនិងរក្សាការងារ, ហើយរបាយការណ៍របស់គេត្រូវបានយកមកប្រើដោយ Centrelink ដើម្បីធ្វើការសម្រេចសំរាប់ផ្តល់ប្រាក់ឧបត្ថម្ភ, ដូចជា សំរាប់ប្រាក់ Disability Support Pension ជាដើម។

## ហេតុអ្វីបានជាខ្ញុំត្រូវការ *Job Capacity Assessment*?

Centrelink ឬស្ថាប័នផ្តល់សេវាប្រកបការងាររបស់លោកអ្នកនឹងប្រាប់លោកអ្នកឲ្យទៅរក *Job Capacity Assessment* ប្រសិនបើ:

- លោកអ្នកដាក់ពាក្យសុំ ឬកំពុងទទួលប្រាក់បំណាច់នៃប្រាក់ឧបត្ថម្ភដែលត្រូវបានធ្វើតេស្តសកម្មភាពដោយ Centrelink, ដូចជា Newstart Allowance ជាដើម, ហើយនិង:
  - លោកអ្នកមានពិការភាព, លក្ខណៈជម្ងឺ ឬឧបសគ្គក្នុងការរកការងារ; ឬ
  - លោកអ្នកដាក់ពាក្យសុំការលើកលែងបញ្ហាពេទ្យរយៈពេលវែងពីតម្រូវការធ្វើតេស្តសកម្មភាព;
- លោកអ្នកទាមទារប្រាក់ Disability Support Pension, ឬប្រាក់ Disability Support Pension របស់លោកអ្នកត្រូវបានពិនិត្យឡើងវិញ; ឬ
- លោកអ្នកចុះឈ្មោះផ្ទាល់ជាមួយស្ថាប័នផ្តល់សេវាប្រកបការងារមួយ, ឬស្ម័គ្រចិត្តចំពោះជំនួយរកការងារធ្វើតាមរយៈ Centrelink (ឧទាហរណ៍ ប្រសិនបើលោកអ្នកទទួលប្រាក់ Disability Support Pension ហើយនឹងចង់បានជំនួយដើម្បីរកការងារធ្វើ)។

សេវាការងារនិងសេវាពាក់ព័ន្ធអាចរកបានដើម្បីជួយលោកអ្នករៀបចំការងារ, រកការងារ ហើយនិងរក្សាការងារឲ្យបានយូរអង្វែងត្រង់ណាដែលសមរម្យ។ សេវាទាំងនេះរួមមានទាំង Job Services Australia, Disability Employment Network, Vocational Rehabilitation Services, ហើយនិង Australian Disability Enterprises.

## តើមានអ្វីកើតឡើងនៅក្នុងការពិនិត្យវាយតម្លៃនេះទេ?

- អ្នកពិនិត្យវាយតម្លៃរបស់លោកអ្នកពិភាក្សាជាមួយលោកអ្នកអំពីឧបសគ្គណាមួយដែលលោកអ្នកប្រហែលជាមានក្នុងការរកការងារធ្វើហើយនិងការរក្សាការងារ។
- អ្នកពិនិត្យវាយតម្លៃរបស់លោកអ្នកក៏ពិគ្រោះជាមួយលោកអ្នកនូវលទ្ធភាពនៃការប្រាប់ឲ្យទៅរកសេវាការងារ ឬសេវាពាក់ព័ន្ធផងដែរ។
- ក្នុងករណីភាគច្រើន, ការពិនិត្យវាយតម្លៃទាំងឡាយទាក់ទិននឹងការពិគ្រោះទល់មុខគ្នារវាងលោកអ្នកនិងអ្នកពិនិត្យវាយតម្លៃនេះ។
- ការពិនិត្យវាយតម្លៃទល់មុខគ្នាទាំងអស់ប្រព្រឹត្តឡើងនៅដាច់ពីគេ, ជាធម្មតានៅក្នុងការិយាល័យរបស់អ្នកពិនិត្យវាយតម្លៃ។
- មិត្តភក្តិ, ញាតិសន្តាន ឬអ្នកគាំទ្រអាចចូលរួមការណាត់ជួបនេះជាមួយលោកអ្នក។
- លោកអ្នកអាចប្រាប់អ្នកដែលធ្វើការណាត់ជួបរបស់លោកអ្នក ប្រសិនបើលោកអ្នកមានការចូលចិត្តអ្នកពិនិត្យវាយតម្លៃប្រុស ឬស្រី។

## តើការពិនិត្យវាយតម្លៃនេះនឹងមានរយៈពេលប៉ុន្មានដែរ?

វាពុំមានការកំណត់ពេលចំពោះការបំពេញការពិនិត្យវាយតម្លៃនេះទេ, តែយ៉ាងណាក៏ដោយ, ជាទូទៅ ការពិនិត្យវាយតម្លៃទាំងឡាយត្រូវប្រើពេលចន្លោះពី 45 ដល់ 90 នាទីហើយប្រហែលជាអាចប្រែប្រួលទៅតាមសេចក្តីត្រូវការរបស់បុគ្គលម្នាក់ៗដែរ។

## តើអ្វីខ្លះដែលខ្ញុំគួរយកទៅតាមនៅក្នុងការណាត់ជួបនេះ?

- ប្រសិនបើលោកអ្នកមានលក្ខណៈជម្ងឺ ឬពិការភាព, សូមយកព័ត៌មានវេជ្ជសាស្ត្រពីវេជ្ជបណ្ឌិត ឬពីស្ថាប័នផ្ដល់ការថែទាំសុខភាពរបស់លោកអ្នកទៅតាមនៅក្នុងការណាត់ជួបរបស់លោកអ្នក។ ប្រសិនបើលោកអ្នកមិនផ្ដល់ភស្តុតាងនៃលក្ខណៈជម្ងឺ ឬពិការភាពទេ, Centrelink ហើយនឹងស្ថាប័នផ្ដល់សេវាប្រកបការងារប្រហែលជាពុំអាចយកលក្ខណៈជម្ងឺ ឬពិការភាពរបស់លោកអ្នកមកពិចារណាពីសារៈសំខាន់សំរាប់គោលបំណងនៃប្រាក់បំណាច់ ឬជំនួយរកការងារទេ។
- ប្រសិនបើលោកអ្នកផ្ដល់របាយការណ៍ពេទ្យ(ឬភស្តុតាងពេទ្យដទៃទៀត) ជាភាគនៃការទាមទារ ឬការពិនិត្យឡើងវិញនៃ Disability Support Pension, Centrelink ផ្ដល់វាទៅឲ្យអ្នកពិនិត្យវាយតម្លៃ។ ប្រសិនបើលោកអ្នកផ្ដល់សំបុត្រពេទ្យទៅឲ្យ Centrelink, វាក៏នឹងត្រូវបានផ្ដល់ទៅឲ្យអ្នកពិនិត្យវាយតម្លៃដែរ។
- វាមិនជាការចាំបាច់យកអ៊ិកស្រេ (X-rays) ឬស្កេន(scan) ទៅតាមនៅក្នុងការណាត់ជួបនេះទេ, ក៏ប៉ុន្តែ លោកអ្នកគួរតែយកទៅតាមខ្លួននូវរបាយការណ៍ណាមួយដែលពន្យល់អំពីលទ្ធផលនៃការធ្វើតេស្តទាំងនេះផងដែរ។
- បញ្ជីឆែកមើលនៅទំព័រទីបីពន្យល់អំពីប្រភេទនៃព័ត៌មានដែលលោកអ្នកប្រហែលជាមានហើយនិងរបៀបដែលជួយ Job Capacity Assessor របស់លោកអ្នក។
- ប្រសិនបើ Job Capacity Assessor ត្រូវការព័ត៌មានថែមទៀតសំរាប់ការពិនិត្យវាយតម្លៃរបស់លោកអ្នកនោះ, គេប្រហែលជាស្នើសុំការអនុញ្ញាតពីលោកអ្នក ដើម្បីទាក់ទងវេជ្ជបណ្ឌិត ឬអ្នកមានវិជ្ជាជីវៈខាងសុខភាពដទៃទៀតរបស់លោកអ្នក, ឬស្នើសុំលោកអ្នកឲ្យយកព័ត៌មាននេះផងដែរ។ អ្នកពិនិត្យវាយតម្លៃក៏ប្រហែលជាពិគ្រោះជាមួយអ្នកពិនិត្យវាយតម្លៃដទៃទៀតដែលមានជំនាញខាងវិស័យណាមួយ។ នៅក្នុងករណីខ្លះ, គេប្រហែលជាបង់ប្រាក់ឲ្យលោកអ្នកទៅធ្វើការពិនិត្យវាយតម្លៃដោយអ្នកឯកទេសពេទ្យ ឬដោយអ្នកចិត្តសាស្ត្រ។

## ចុះប្រសិនបើខ្ញុំត្រូវការអ្នកបកប្រែភាសា ឬតម្រូវការពិសេសៗនោះ?

ប្រសិនបើបានតម្រូវ, Job Capacity Assessor របស់លោកអ្នកនឹងរៀបចំអ្នកបកប្រែភាសាម្នាក់ដែលមានជំនាញគ្រប់លក្ខណៈ, រួមមានទាំងអ្នកបកប្រែភាសាសញ្ញា Auslan, ដើម្បីជួយការពិនិត្យវាយតម្លៃរបស់លោកអ្នក។ លោកអ្នកត្រូវការប្រាប់អ្នកដែលកំពុងធ្វើការណាត់ជួបសំរាប់ Job Capacity Assessment ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា ឬមានតម្រូវការពិសេសណាមួយ។

## តើមានអ្វីកើតឡើងនៅក្រោយការពិនិត្យវាយតម្លៃនេះទេ?

- ទីណាដែលអាចធ្វើទៅបាន, លោកអ្នកនឹងត្រូវបានប្រាប់ឲ្យទៅរកសេវាខាងការងារ ឬសេវាជាប់ទាក់ទិនដើម្បីជួយលោកអ្នករកនិងរក្សាការងារ។ ក្នុងករណីភាគច្រើន, ការប្រាប់ទៅរកព័ត៌មានលំអិតត្រូវបានផ្ដល់ឲ្យនៅពេលលោកអ្នកបំពេញការពិនិត្យវាយតម្លៃរបស់លោកអ្នក។
- Job Capacity Assessor របស់លោកអ្នករៀបចំរបាយការណ៍មួយអំពីសមត្ថភាពធ្វើការងាររបស់លោកអ្នក។ របាយការណ៍នេះត្រូវបានផ្ដល់ទៅឲ្យ Centrelink, ហើយត្រង់ណាដែលអាចអនុវត្តទៅបាន, សេចក្ដីសម្រេចមួយត្រូវបានធ្វើអំពីសិទ្ធិរបស់លោកអ្នកសំរាប់ទទួលយកប្រាក់ឧបត្ថម្ភ ឬតម្រូវការធ្វើតេស្តសកម្មភាព។ របាយការណ៍នេះក៏ផ្ដល់ព័ត៌មានទៅឲ្យ Centrelink ដែរ ហើយនិង/ឬ ស្ថាប័នផ្ដល់សេវាប្រកបការងារ ឬសេវាទាក់ទិនរបស់លោកអ្នកអំពីលទ្ធភាពលោកអ្នកក្នុងការរកការងារធ្វើ, ហើយនិងការគាំទ្រ ឬសេវាសមរម្យណាមួយដែលលោកអ្នកត្រូវការ។
- សេចក្ដីសម្រេចទាំងឡាយអំពីតម្រូវការនៃប្រាក់ឧបត្ថម្ភ ឬតេស្តសកម្មភាពរបស់លោកអ្នកត្រូវបានធ្វើឡើងដោយ Centrelink, មិនមែនអ្នកពិនិត្យវាយតម្លៃទេ។
- ចំពោះព័ត៌មានថែមទៀតអំពីសេវាការងារគ្រប់គ្រងដោយ Department of Education, Employment and Workplace Relations សូមទៅរកវេបសៃ **www.workplace.gov.au** ឬទូរស័ព្ទទៅលេខ **13 62 68**។
- ចំពោះព័ត៌មានថែមទៀតអំពីប្រាក់ឧបត្ថម្ភហើយនិងតម្រូវការនៃតេស្តសកម្មភាព, សូមទាក់ទងខ្សែទូរស័ព្ទទាន់ចិត្តរបស់ Centrelink's Disability, Sickness and Carers តាមលេខ **13 27 17** ឬខ្សែទូរស័ព្ទទាន់ចិត្តនៃសេវាប្រកបការងារតាមលេខ **13 28 50**។

## តើមានអ្វីកើតឡើងទេ ប្រសិនបើខ្ញុំពុំអាចចូលរួមការណាត់ជួបរបស់ខ្ញុំនោះ?

ប្រសិនបើលោកអ្នកពុំអាចចូលរួមការណាត់ជួបទេដោយសារកាលៈទេសៈពិសេសនានា, លោកអ្នកត្រូវតែទាក់ទង Job Capacity Assessor របស់លោកអ្នកឲ្យបានឆាប់ជាទីបំផុត។ លេខទូរស័ព្ទត្រូវបានចុះនៅក្នុងព័ត៌មានលំអិតនៃការណាត់ជួបរបស់លោកអ្នក។

ប្រសិនបើលោកអ្នកកំពុងទាមទារ ឬទទួលប្រាក់បំណាច់មួយពី Centrelink:

- Centrelink នឹងប្រាប់លោកអ្នកថាតើលោកអ្នកត្រូវតែចូលរួមការណាត់ជួបរបស់លោកអ្នក; ហើយនិង
- ប្រសិនបើលោកអ្នកមិនចូលរួមការពិនិត្យវាយតម្លៃនេះទេ Job Capacity Assessor នឹងឲ្យឱវាទទៅ Centrelink ហើយនិង/ឬ ស្ថាប័នផ្ដល់សេវាប្រកបការងាររបស់លោកអ្នក។ ប្រសិនបើលោកអ្នកកំពុងទទួលប្រាក់បំណាច់នៃតេស្តសកម្មភាព, ដូចជា Newstart Allowance, Centrelink ប្រហែលជាបញ្ឈប់ប្រាក់បំណាច់នៃប្រាក់ឧបត្ថម្ភរបស់លោកអ្នករហូតដល់លោកអ្នកចូលរួមការពិនិត្យវាយតម្លៃនេះ។ ប្រសិនបើលោកអ្នកកំពុងដាក់ពាក្យសុំប្រាក់ Disability Support Pension, Centrelink ប្រហែលជាមិនទទួលការទាមទាររបស់លោកអ្នកទេ។

## ពាក្យបណ្ដឹង

- ប្រសិនបើលោកអ្នកមានកង្វល់អំពីរបៀបពិនិត្យវាយតម្លៃរបស់លោកអ្នកដែលត្រូវបានធ្វើមកនោះ លោកអ្នកគួរតែពិភាក្សាជាមួយ Job Capacity Assessor ជាមុនសិនដែលបានធ្វើការពិនិត្យវាយតម្លៃរបស់លោកអ្នក។
- ប្រសិនបើលោកអ្នកនៅតែមានកង្វល់ទៀតក្រោយពីការពិភាក្សាជាមួយអ្នកពិនិត្យវាយតម្លៃនោះ, លោកអ្នកអាចដាក់ពាក្យបណ្ដឹងតាមខ្សែទូរស័ព្ទផ្នែកទំនាក់ទំនងអតិថិជនគឺ Centrelink's FreeCall™ លេខ **1800 050 004*** ឬ ទូរស័ព្ទផ្នែកសេវាទំនាក់ទំនងអតិថិជន Centrelink's TTY លេខ **1800 000 567** (សំរាប់តែជនដែលថ្លង់ ឬអន់ខ្សោយក្នុងការស្ដាប់ ឬក្នុងការនិយាយហើយមានលទ្ធភាពប្រើទូរស័ព្ទ TTY) ហើយបណ្ដឹងរបស់លោកអ្នកនឹងត្រូវបានស៊ើបអង្កេត។
- ប្រសិនបើលោកអ្នកមិនពេញចិត្តនឹងសេចក្ដីសម្រេចរបស់ Centrelink ឬអំពើរបស់ Job Capacity Assessor ទេ, លោកអ្នកអាចដាក់ពាក្យបណ្ដឹងទៅ Commonwealth Ombudsman ដោយទូរស័ព្ទលេខ **1300 362 072**, ជាលាយលក្ខណ៍អក្សរទៅ GPO Box 442, Canberra, ACT, 2601 ឬតាមអ៊ិនធឺណេតគឺ **www.ombudsman.gov.au**។ មុននឹងពិនិត្យពាក្យបណ្ដឹងមួយ Ombudsman ប្រហែលជាស្នើសុំឲ្យលោកអ្នកទាក់ទងខ្សែទូរស័ព្ទ Centrelink's FreeCall™ សំរាប់ទំនាក់ទំនងអតិថិជនជាមុនសិន។

## ភាពឯកជន

- Job Capacity Assessors ត្រូវបានតម្រូវឲ្យការពារភាពឯកជនរបស់លោកអ្នក ហើយនិងផ្ដល់នូវសេវាយ៉ាងសម្ងាត់ផងដែរ។
- ព័ត៌មានផ្ទាល់ខ្លួនណាមួយអំពីលោកអ្នកដែលបានប្រមូលផ្ដុំ ឬរក្សាទុកនោះត្រូវបានការពារដោយច្បាប់។ ព័ត៌មានរបស់លោកអ្នកត្រូវបានឲ្យទៅអ្នកណាម្នាក់ទៀតក្នុងកាលៈទេសៈដែលអនុញ្ញាត ឬតម្រូវដោយច្បាប់ Commonwealth ឬនៅពេលដែលលោកអ្នកឲ្យការអនុញ្ញាតតែប៉ុណ្ណោះ។
- លោកអ្នកអាចធ្វើសំណើទៅ Centrelink ក្រោមក្រិត្យ Freedom of Information Act 1982 ដើម្បីមើលរបាយការណ៍ *Job Capacity Assessment* របស់លោកអ្នក។

លោកអ្នកអាចរកព័ត៌មានថែមទៀតអំពី Job Capacity Assessments ដោយបើកមើលវែបសៃ **www.jca.gov.au**

ព័ត៌មានដែលមាននៅក្នុងការបោះពុម្ពផ្សាយនេះត្រូវបានបម្រុងទុកជាការណែនាំតែប៉ុណ្ណោះ។

## បញ្ជីឆែកមើលភស្តុតាងពេទ្យសំរាប់ Job Capacity Assessment

ឧទាហរណ៍នៃប្រភេទព័ត៌មាន ឬភស្តុតាងអំពីលក្ខណៈជម្ងឺ ឬពិការភាពរបស់លោកអ្នកដែលលោកអ្នកគួរតែយកទៅកាន់ *Job Capacity Assessment* របស់លោកអ្នករួមមានទាំង:

| | |
|---|---|
| របាយការណ៍ពេទ្យ-ប្រាក់សោធនឧបត្ថម្ភអ្នកមានពិការភាព | ☐ |
| សំបុត្រពេទ្យCentrelink | ☐ |
| ស្ដង់ដារនៃសំបុត្រពេទ្យ GP (វេជ្ជបណ្ឌិតទូទៅ) | ☐ |
| របាយការណ៍ពេទ្យនៃអ្នកឯកទេសពេទ្យ | ☐ |
| របាយការណ៍របស់អ្នកចិត្តសាស្ត្រ/លទ្ធផលតេស្តបញ្ញានិងបុគ្គលិកលក្ខណៈ(psychometric test ) | ☐ |
| របាយការណ៍នៃសាលាពិសេស | ☐ |
| ថ្នាំពេទ្យដែលមានសំបុត្រពេទ្យ/គំរូថ្នាំពេទ្យ | ☐ |
| របាយការណ៍នៃមន្ទីរពេទ្យ/អ្នកជម្ងឺក្រៅមន្ទីរពេទ្យ | ☐ |
| របាយការណ៍ពីសេវាសហគមន៍ | ☐ |
| ព័ត៌មានពីស្ថាប័នផ្ដល់សេវាប្រកបការងាររបស់លោកអ្នក | ☐ |

Job Capacity Assessor របស់លោកអ្នកពិចារណាពីសារៈសំខាន់នៃព័ត៌មានហើយនិងភស្តុតាងទាំងអស់ដែលលោកអ្នកយកទៅតាមនៅក្នុងការពិនិត្យវាយតម្លៃនេះនៅពេលរៀបចំរបាយការណ៍នេះ។

ប្រសិនបើលោកអ្នកត្រូវការពេលវេលាថែមទៀតដើម្បីផ្ដល់ភស្តុតាងពេទ្យ, លោកអ្នកអាចស្នើសុំឲ្យគេរៀបចំការណាត់ជួបរបស់លោកអ្នកម្ដងទៀត។ ប្រសិនបើលោកអ្នកមានបញ្ហាក្នុងការផ្ដល់ភស្តុតាងពេទ្យ, សូមប្រាប់អ្នកពិនិត្យវាយតម្លៃរបស់លោកអ្នក។

ប្រសិនបើលោកអ្នកមិនផ្ដល់ភស្តុតាងពេទ្យទេ:

- លោកអ្នកប្រហែលជាមិនមានលក្ខណៈគ្រប់គ្រាន់នឹងទទួលប្រាក់បំណាច់នៃប្រាក់ឧបត្ថម្ភហើយនិងសម្បទាននៃជំនួយសង្គមកិច្ច;
- លក្ខណៈជម្ងឺ ឬពិការភាពរបស់លោកអ្នកប្រហែលជាមិនត្រូវបានយកមកពិចារណាពីសារៈសំខាន់នៅពេលដែលតម្រូវការធ្វើតេស្តសកម្មភាពរបស់លោកអ្នកត្រូវបានកំណត់; ហើយនិង
- លោកអ្នកប្រហែលជាមិនមានលក្ខណៈគ្រប់គ្រាន់នឹងបានការងារសមរម្យបំផុត ឬទទួលសេវាគាំទ្រ។

## ចំពោះព័ត៌មានថែមទៀត សូមបើកមើលវែបសៃ www.jca.gov.au